ACT Government

ACT LEAVE

# អាជ្ញាធរច្បាប់ឈប់សម្រាកដោយមានបៀវត្សសម្រាប់អតីតភាពការងារច្រើនឆ្នាំ

### *តើអ្វីទៅជាសិទ្ធិឈប់សម្រាកដោយមានបៀវត្ស ដែលអាចផ្ទេរបាន សម្រាប់អតីតភាពការងារច្រើនឆ្នាំ?*

ប្រសិនបើអ្នកធ្វើការនៅក្នុងឧស្សាហកម្មសាងសង់ និងសំណង់ សេវាសហគមន៍ សេវាសម្អាតដោយមានកិច្ចន្យា ឬសន្តិសុខនៅក្នុងច្បាប់នេះ សិទ្ធិឈប់សម្រាកដោយមានបៀវត្ស ដែលអាចផ្ទេរបាន សម្រាប់អតីតភាពការងារច្រើនឆ្នាំគឺជាប្រភេទនៃសិទ្ធិឈប់សម្រាកមានប្រាក់បៀវត្សរ៍ដែលអ្នកអាចប្រើប្រាស់បាន បន្ទាប់ពីអ្នកបានធ្វើការនៅក្នុងឧស្សាហកម្មណាមួយក្នុងចំណោមឧស្សាហកម្មទាំងនោះក្នុងរយៈពេលជាក់លាក់ណាមួយ។ ទោះជាអ្នកបានធ្វើការឱ្យនិយោជកខុសៗគ្នាក៏ដោយ ឲ្យតែអ្នកបានធ្វើការងារនៅក្នុងវិស័យឧស្សាហកម្មដូចគ្នាសម្រាប់ពេលវេលាចាំបាច់។

- ប្រសិនបើអ្នកធ្វើការនៅ***ក្នុងវិស័យសាងសង់ និងសំណង់*** អ្នកនឹងមានសិទ្ធិទទួលបានការឈប់សម្រាក 13 សប្តាហ៍ដោយមានប្រាក់បៀវត្សរ៍ បន្ទាប់ពីអ្នកបានធ្វើការនៅក្នុងវិស័យឧស្សាហកម្មនេះអស់រយៈពេល 10 ឆ្នាំ។
- ប្រសិនបើអ្នកធ្វើការនៅ***ក្នុងវិស័យសេវាសហគមន៍*** អ្នកនឹងមានសិទ្ធិទទួលបានការឈប់សម្រាក 4.33 សប្តាហ៍ដោយមានប្រាក់បៀវត្សរ៍ បន្ទាប់ពីអ្នកបានធ្វើការនៅក្នុងវិស័យឧស្សាហកម្មនេះអស់រយៈពេល 5 ឆ្នាំ។
- ប្រសិនបើអ្នកធ្វើការនៅ***ក្នុងវិស័យសេវាសម្អាតដោយមានកិច្ចសន្យា*** អ្នកនឹងមានសិទ្ធិទទួលបានការឈប់សម្រាក 6.06 សប្តាហ៍ដោយមានប្រាក់បៀវត្សរ៍ បន្ទាប់ពីអ្នកបានធ្វើការនៅក្នុងវិស័យឧស្សាហកម្មនេះអស់រយៈពេល 7 ឆ្នាំ។
- ប្រសិនបើអ្នកធ្វើការនៅ***ក្នុងវិស័យសេវាសន្តិសុខ*** អ្នកនឹងមានសិទ្ធិទទួលបានការឈប់សម្រាក 6.06 សប្តាហ៍ដោយមានប្រាក់បៀវត្សរ៍ បន្ទាប់ពីអ្នកបានធ្វើការនៅក្នុងវិស័យឧស្សាហកម្មនេះអស់រយៈពេលប្រាំពីរឆ្នាំ។

### *តើអ្វីជាអាជ្ញាធរច្បាប់ឈប់សម្រាកដោយមានបៀវត្ស សម្រាប់អតីតភាពការងារច្រើនឆ្នាំ?*

យើងគឺជាស្ថាប័នរដ្ឋដែលទទួលខុសត្រូវក្នុងការពិនិត្យមើលច្បាប់ឈប់សម្រាកដោយមានបៀវត្ស ដែលអាចផ្ទេរបាន សម្រាប់អតីតភាពការងារច្រើនឆ្នាំរបស់អ្នក។

### *តើខ្ញុំដឹងដោយរបៀបណាថាតើខ្ញុំបានចុះឈ្មោះឬអត់?*

ប្រសិនបើអ្នកកំពុងធ្វើការនៅក្នុងឧស្សាហកម្មសាងសង់ និងសំណង់ សេវាសហគមន៍ សេវាសម្អាតដោយមានកិច្ចសន្យា ឬសន្តិសុខ និយោជករបស់អ្នកត្រូវតែចុះឈ្មោះអ្នកជាមួយយើងដើម្បីទទួលការឈប់សម្រាកដោយមានបៀវត្សសម្រាប់អតីតភាពការងារច្រើនឆ្នាំនៅពេលអ្នកចាប់ផ្តើមធ្វើការឱ្យពួកគេ។ បន្ទាប់ពីអ្នកបានចុះឈ្មោះហើយ យើងផ្ញើលិខិតមួយច្បាប់ទៅអ្នក ហើយប្រាប់អ្នកអំពីព័ត៌មានលម្អិតនៃការចុះឈ្មោះរបស់អ្នក។ ប្រសិនបើអ្នកមិនបានទទួលលិខិតនេះ ឬអ្នកមិនប្រាកដថាអ្នកបានចុះឈ្មោះទេនោះ អ្នកគួរតែទាក់ទងមកយើងដើម្បីឲ្យប្រាកដថា យើងបានកត់ត្រាព័ត៌មានលម្អិតរបស់អ្នក។

បន្ទាប់ពីអ្នកបានចុះឈ្មោះ
អ្នកគួរតែទទួលបានលិខិតបញ្ជាក់មួយច្បាប់ពីយើងនៅខែតុលាជារៀងរាល់ឆ្នាំដែលនឹងបញ្ជាក់ប្រាប់អ្នកអំពីចំនួនថ្ងៃដែលអ្នកបានធ្វើការនៅក្នុងឆ្នាំនេះ តើនិយោជកណាខ្លះដែលអ្នកបានធ្វើការឲ្យក្នុងអំឡុងរយៈពេលឆ្នាំនេះ និងប្រាក់ឈ្នួលដែលបានកត់ត្រាទុកសម្រាប់អ្នក។ ព័ត៌មាននេះមានសារសំខាន់ខ្លាំងណាស់ ហើយវាត្រូវបានប្រើប្រាស់ ដើម្បីគណនារយៈពេលនៃការឈប់សម្រាកដោយមានបៀវត្ស ដែលអាចផ្ទេរបាន សម្រាប់អតីតភាពការងារច្រើនឆ្នាំរបស់អ្នក។ នៅពេលអ្នកទទួលបានលិខិតបញ្ជាក់របស់អ្នកជារៀងរាល់ឆ្នាំ អ្នកគួរតែពិនិត្យមើលថាព័ត៌មាននេះត្រឹមត្រូវឬអត់។ ប្រសិនបើអ្នកគិតថាលិខិតបញ្ជាក់របស់អ្នកខ្វះព័ត៌មានណាមួយ ឬចំណុចណាមួយមើលទៅខុស អ្នកគួរតែទាក់ទងមកយើងដើម្បីធ្វើការពិនិត្យ។ ប្រសិនបើអ្នកមិនបានទទួលលិខិតបញ្ជាក់ណាមួយ សូមមេត្តាឲ្យយើងឲ្យដឹង។ យើងប្រហែលជាមិនមានព័ត៌មានលម្អិតត្រឹមត្រូវសម្រាប់ទំនាក់ទំនងជាមួយអ្នក ឬអ្នកប្រហែលជាមិនបានចុះឈ្មោះ។

### *តើខ្ញុំគួរតែធ្វើដូចម្តេច ប្រសិនបើខ្ញុំត្រូវការព័ត៌មានអំពីការឈប់សម្រាកដោយមានបៀវត្ស ដែលអាចផ្ទេរបាន សម្រាប់អតីតភាពការងារច្រើនឆ្នាំរបស់ខ្ញុំ?*

ប្រសិនបើអ្នកចង់បានព័ត៌មានអំពីការឈប់សម្រាកដោយមានបៀវត្ស ដែលអាចផ្ទេរបាន សម្រាប់អតីតភាពការងារច្រើនឆ្នាំរបស់អ្នក សូមទូរស័ព្ទមកយើងតាមរយៈលេខ៖ 02 6247 3900 ឬផ្ញើអ៊ីម៉ែលមកយើងខ្ញុំតាមអាសយដ្ឋាន៖ enquiry@actleave.act.gov.au។
ប្រសិនបើអ្នកត្រូវការនិយាយជាមួយនរណាម្នាក់ជាភាសាផ្សេងក្រៅពីភាសាអង់គ្លេស សូមទូរស័ព្ទទៅផ្នែកសេវាបកប្រែតាមទូរស័ព្ទតាមរយៈលេខ៖ 131 450។